ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៦៦៣...សហវ....ប្រក


# ប្រកាស
## ស្តីពី
## នីតិវិធីចំណាយតាមរបបបុរេប្រទាន
## សម្រាប់រដ្ឋបាលថ្នាក់ជាតិ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩និងមាត្រា១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា




ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងបង្កើនប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃចំណាយតាមរជ្ជទេយ្យបុរេប្រទានប្រកបដោយភាពទាន់ពេល តម្លាភាព និងគណនេយ្យភាព។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅកំណត់នីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែលនៃរដ្ឋបាលថ្នាក់ជាតិដែលអនុវត្តនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន លើកលែងតែគ្រឹះស្ថានសាធារណៈរដ្ឋបាលនិងអង្គភាពប្រហាក់ប្រហែលដែលមាននីតិវិធីអនុវត្តដោយឡែក។

**ប្រការ៤.-**

ក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល សំដៅដល់ក្រសួង ស្ថាប័ន អង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិ និងអាជ្ញាធរក្រោមឱវាទក្រសួង ស្ថាប័ននៃរដ្ឋបាលថ្នាក់ជាតិ។

## ជំពូកទី២

## ការបង្កើតរជ្ជទេយ្យបុរេប្រទាន ការតែងតាំងនិងការទទួលខុសត្រូវរបស់រជ្ជទេយ្យករបុរេប្រទាន

### ផ្នែកទី១

### ការបង្កើតរជ្ជទេយ្យបុរេប្រទាន

**ប្រការ៥.-**

រជ្ជទេយ្យបុរេប្រទានគឺជាចំណាយលើដំណើរការរដ្ឋបាលដែលមានលក្ខណៈជាប្រចាំ បន្ទាន់ និងមានចំនួនទឹកប្រាក់តិចតួច ដែលពុំអាចរង់ចាំការបោះផ្សាយអាណត្តិបើកប្រាក់តាមនីតិវិធីទូទាត់ត្រង់បាន ជាអាទិ៍រួមមាន ចំណាយលើការទិញសម្ភារតិចតួច និងសេវាកម្មតូចតាច ជាដើម។

**ប្រការ៦.-**

តារាងឧបសម្ពន្ធរជ្ជទេយ្យបុរេប្រទានត្រូវបង្កើតឡើងដោយជ្រើសរើសយកមាតិកាចំណាយតាមគណនី និងអនុគណនីនៃជំពូក៦០ "ការទិញ" ជំពូក៦១ "សេវាកម្ម" និងជំពូក៦៥ "ឧបត្ថម្ភធន" ដោយត្រូវគិតក្នុងកម្រិតមិនឱ្យលើសពី៣០ភាគរយនៃឥណទានថវិកាតាមជំពូកដែលជ្រើសរើសក្នុងក្របខ័ណ្ឌកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល ដោយដកទំហំថវិកាសម្រាប់ចំណាយតាមនីតិវិធីទូទាត់ត្រង់ ដែលជាប្រភេទចំណាយតម្រូវឱ្យមានការស្នើសុំធានាចំណាយ និងចំណាយដែលតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ។ ទំហំថវិកាដែលជ្រើសរើសពីអនុគណនី ត្រូវកម្រិតមិនឱ្យលើសពី៣០ភាគរយនៃឥណទានថវិកាសរុបតាមអនុគណនីនីមួយៗ លើកលែងតែមុខសញ្ញាចំណាយមួយចំនួនដែលត្រូវបានអនុញ្ញាតឱ្យលើសពី៣០ភាគរយទៅតាមតម្រូវការចាំបាច់នៃចំណាយ ប៉ុន្តែត្រូវរក្សាកម្រិតអតិបរមាមិនឱ្យលើសពី៣០ភាគរយនៃឥណទានថវិកាតាមជំពូកដែលបានជ្រើសរើសយកមកបង្កើតរជ្ជទេយ្យបុរេប្រទាននោះឡើយ។ មុខសញ្ញាចំណាយទាំងនេះត្រូវបានកំណត់លម្អិតក្នុងឧបសម្ពន្ធទី១នៃប្រកាសនេះ។

**ប្រការ៧.-**

តារាងឧបសម្ពន្ធរជ្ជទេយ្យបុរេប្រទានមាន ២ (ពីរ)ប្រភេទគឺ (១)- តារាងឧបសម្ពន្ធតាមចំណាត់ថ្នាក់សេដ្ឋកិច្ច (ជំពូក គណនី និងអនុគណនី) និង(២)- តារាងឧបសម្ពន្ធតាមចំណាត់ថ្នាក់កម្មវិធី (កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព)ដូចមានកំណត់ជាឧបសម្ពន្ធទី២នៃប្រកាសនេះ។

ដើម្បីឱ្យការរៀបចំបង្កើតរជ្ជទេយ្យបុរេប្រទានបានឆាប់រហ័ស ទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ត្រូវអនុវត្តតាមពេលវេលាកំណត់ដូចខាងក្រោម÷

- ការរៀបចំផែនការឥណទានរជ្ជទេយ្យបុរេប្រទានត្រូវធ្វើឡើងដំណាលគ្នានឹងការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំសម្រាប់ពិនិត្យនិងពិភាក្សាក្នុងកិច្ចប្រជុំការពារគម្រោងថវិកាប្រចាំឆ្នាំ។ ក្នុងអំឡុងពេលប្រជុំការពារគម្រោងថវិកា មិនតម្រូវឱ្យពិនិត្យមើលលម្អិតលើតារាងឧបសម្ពន្ធរជ្ជទេយ្យបុរេប្រទានទេ ប៉ុន្តែក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល ត្រូវធានាថាឥណទានថវិកាដែលត្រូវយកមករៀបចំតារាងឧបសម្ពន្ធរជ្ជទេយ្យបុរេប្រទាន មិនត្រូវត្រួតស៊ីគ្នានឹងឥណទានថវិកាដែល

ត្រូវបានគ្រោងទុកសម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈតាមនីតិវិធីទូទាត់ត្រង់ និងនីតិវិធីចំណាយផ្សេងទៀត

- ក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល ត្រូវរៀបចំតារាងឧបសម្ពន្ធរជ្ជទេយ្យបុរេប្រទាន តាមគំរូតារាងឧបសម្ពន្ធរជ្ជទេយ្យបុរេប្រទានខាងលើ ដោយផ្អែកតាមលទ្ធផលនៃការពិភាក្សាការពារគម្រោងថវិកានិងបទប្បញ្ញត្តិនៃប្រកាសនេះ
- ក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល ត្រូវរៀបចំលិខិតស្នើសុំបង្កើតរជ្ជទេយ្យបុរេប្រទាន និងបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយជុំបង្វិលដំបូង រួចបញ្ជូនមកអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ និងគណនេយ្យករសាធារណៈ ដោយភ្ជាប់មកជាមួយនូវតារាងឧបសម្ពន្ធរជ្ជទេយ្យបុរេប្រទានដែលចុះហត្ថលេខារួច ដោយអាណាប័កដើមខ្សែឬអាណាប័កផ្ទេរសិទ្ធិ យ៉ាងយូរបំផុតត្រឹមសប្ដាហ៍ទី៣នៃខែវិច្ឆិកា (មុនឆ្នាំអនុវត្តថវិកា)។ គំរូលិខិតស្នើសុំបង្កើតរជ្ជទេយ្យបុរេប្រទាន និងបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយជុំបង្វិលដំបូង មានភ្ជាប់ជាឧបសម្ពន្ធទី៣នៃប្រកាសនេះ
- អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ នៅពេលទទួលបានលិខិតស្នើសុំបង្កើតរជ្ជទេយ្យបុរេប្រទាន និងបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយជុំបង្វិលដំបូងពីក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល ត្រូវពិនិត្យលើតារាងឧបសម្ពន្ធរជ្ជទេយ្យបុរេប្រទានដើម្បីធានាថា ការរៀបចំនេះអនុលោមតាមលក្ខខណ្ឌ និងបទប្បញ្ញត្តិផ្សេងៗនៃប្រកាសនេះ។ នៅពេលពិនិត្យឃើញថាមានអនុលោមភាពហើយ ត្រូវចុះហត្ថលេខាឯកភាពលើតារាងឧបសម្ពន្ធរជ្ជទេយ្យបុរេប្រទាន និងបញ្ជូនមកគណនេយ្យករសាធារណៈដើម្បីមុខការបន្ត។ ប្រសិនបើពិនិត្យឃើញថាមិនមានអនុលោមភាពទេ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុត្រូវស្នើសុំការពន្យល់បន្ថែមពីក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល ឬ បញ្ជូនសំណើនេះទៅក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែលវិញ ដើម្បីកែតម្រូវដោយត្រូវបង្ហាញពីចំណុចខ្វះខាតនៃសំណើនេះ
- គណនេយ្យករសាធារណៈ ក្រោយទទួលបានលិខិតស្នើសុំបង្កើតរជ្ជទេយ្យបុរេប្រទាន និងបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយជុំបង្វិលដំបូង ដែលទទួលបានការមិនយល់ទាស់ពីអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវពិនិត្យអនុលោមភាពនិងចុះហត្ថលេខាឯកភាពលើតារាងឧបសម្ពន្ធរជ្ជទេយ្យបុរេប្រទាន ព្រមទាំងរៀបចំលិខិតជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចុះហត្ថលេខា ដើម្បីបញ្ជាបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយជុំដំបូងជូនក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល តាមចំនួនទឹកប្រាក់ដែលមានក្នុងតារាងឧបសម្ពន្ធរជ្ជទេយ្យបុរេប្រទាននេះ។ ប្រសិនបើពិនិត្យឃើញថាមិនមានអនុលោមភាព គណនេយ្យករសាធារណៈត្រូវស្នើសុំការពន្យល់បញ្ជាក់បន្ថែមពីអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ឬ ក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល។ ក្នុងករណីចាំបាច់ គណនេយ្យករសាធារណៈអាចបញ្ជូនសំណើនេះទៅក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែលវិញ ដើម្បីកែតម្រូវដោយត្រូវបង្ហាញពី

ចំណុចខ្វះខាតនៃសំណើនេះ។ គំរូលិខិតអនុញ្ញាតឱ្យបង្កើតរជ្ជទេយ្យបុរេប្រទាន និងបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយដុំបង្វិលដំបូងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភ្ជាប់ជាឧបសម្ព័ន្ធទី៤នៃប្រកាសនេះ

- ដើម្បីជៀសវាងការរអាក់រអួលក្នុងការរៀបចំ ឬ ដើម្បីឱ្យការរៀបចំតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេ-ប្រទានប្រព្រឹត្តទៅដោយរលូន ក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល ត្រូវបានលើកទឹកចិត្តឱ្យធ្វើការពិគ្រោះយោបល់ជាបណ្តើរៗជាមួយនឹងអ្នកត្រួតពិនិត្យហិរញ្ញវត្ថុនិង/ឬគណនេយ្យករសាធារណៈ
- ទិន្នន័យឥណទានថវិការជ្ជទេយ្យបុរេប្រទានសម្រាប់ឆ្នាំថវិកាបន្ទាប់ ត្រូវបញ្ចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ឱ្យបានរួចរាល់មុនដំណាច់ខែធ្នូ (មុនឆ្នាំអនុវត្តថវិកា)
- ក្នុងករណីដែលសំណើសុំបង្កើតរជ្ជទេយ្យបុរេប្រទាន និងបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយដុំបង្វិលដំបូងរបស់ក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល មិនត្រូវបានអនុម័តទាន់ពេលវេលានៅសប្តាហ៍ទី២ ក្នុងខែធ្នូ (មុនឆ្នាំអនុវត្តថវិកា) នោះទេ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ និងគណនេយ្យករសាធារណៈត្រូវអនុម័តតួលេខឥណទានថវិការជ្ជទេយ្យបុរេប្រទាននៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដើម្បីអាចបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយដុំបង្វិលដំបូងបានទាន់ពេលវេលា នៅដើមឆ្នាំអនុវត្តថវិកា។ ចំណែកឯឯកសារស្នើសុំត្រូវបន្តឆ្លងដំណើការពិនិត្យនិងអនុម័តតាមក្រោយ។
- ក្នុងករណីក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល មិនបានបញ្ជូនលិខិតស្នើសុំបង្កើតរជ្ជទេយ្យបុរេប្រទាន និងបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយដុំបង្វិលដំបូងមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានមុនដំណាច់ខែវិច្ឆិកាទេ គឺចាត់ទុកថា ក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល ពុំមានបំណងបង្កើតរជ្ជទេយ្យបុរេប្រទានក្នុងឆ្នាំថវិកាបន្ទាប់ទេ ។ ដូច្នេះ គម្រោងរជ្ជទេយ្យបុរេប្រទានដែលបានពិនិត្យក្នុងអំឡុងពេលកិច្ចប្រជុំពិភាក្សាការពារគម្រោងថវិកា ត្រូវចាត់ទុកជាមោឃៈដោយត្រូវអនុវត្តតាមនីតិវិធីទូទាត់ត្រង់ ឬនីតិវិធីផ្សេងទៀត។

**ប្រការ៨.-**

ក្នុងករណីមានតម្រូវការចាំបាច់ក្នុងអំឡុងពេលអនុវត្តថវិកា ក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់-ប្រហែល អាចកែសម្រួលតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានបាន ប៉ុន្តែការកែសម្រួលនោះមិនត្រូវឱ្យលើសពី៣(បី)លើកក្នុង១ឆ្នាំថវិកាឡើយ។ ការកែសម្រួលលើកទី១អាចអនុវត្តចាប់ពីខែមេសា លើកទី២ក្នុងអំឡុងខែកក្កដា និងលើកទី៣ដែលជាលើកចុងក្រោយ ត្រូវកែសម្រួលឱ្យរួចរាល់មិនឱ្យហួសថ្ងៃទី១០ ខែវិច្ឆិកា ទេ។ ក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល ត្រូវធានាថា ការកែសម្រួលនេះបានរក្សាទុកឥណទានថវិកាគ្រប់គ្រាន់សម្រាប់ទូទាត់រជ្ជទេយ្យបុរេប្រទានដែលបានអនុវត្តរួច ដោយមិនឱ្យប៉ះពាល់ដល់

ឥណទានថវិកាដែលបានត្រៀមទុកសម្រាប់ទូទាត់មុខសញ្ញាចំណាយកិច្ចលទ្ធកម្មសាធារណៈ ចំណាយទូទាត់ត្រង់ និងប្រភេទចំណាយផ្សេងៗទៀត ហើយមិនត្រូវហួសពិតានភាគរយដែលបានកំណត់និងផ្ទុយពីបទប្បញ្ញត្តិផ្សេងៗដែលមានចែងក្នុងប្រកាសនេះឡើយ។

បន្ទាប់ពីកែសម្រួលរួចហើយ ក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល ត្រូវផ្ញើតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានកែសម្រួលនោះមកអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ និងគណនេយ្យករសាធារណៈដើម្បីអនុម័តតួលេខឥណទានថវិកាកែតម្រូវនៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និងជាឯកសារសម្រាប់ត្រួតពិនិត្យផ្ទៀងផ្ទាត់នៅពេលទូទាត់។

គំរូតារាងកែសម្រួលឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងតាមចំណាត់ថ្នាក់កម្មវិធី ត្រូវបានកំណត់ជាឧបសម្ព័ន្ធទី៥នៃប្រកាសនេះ។

**ប្រការ៩.-**

ទឹកប្រាក់នៃជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់១/៤(មួយភាគបួន)នៃឥណទានថវិការជ្ជទេយ្យបុរេប្រទាន។

យន្តការនៃជុំបង្វិលរជ្ជទេយ្យបុរេប្រទាន និងការបំពេញបេឡារជ្ជទេយ្យបុរេប្រទានឡើងវិញ ត្រូវធ្វើឡើងតាមគោលការណ៍ ដូចខាងក្រោម÷

- ទឹកប្រាក់រជ្ជទេយ្យបុរេប្រទានដំបូងត្រូវកំណត់ចំនួនតិចជាង ឬ ស្មើនឹងទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ដោយពុំចាំបាច់បញ្ជាក់អំពីមុខសញ្ញាចំណាយ
- ការទូទាត់រជ្ជទេយ្យបុរេប្រទានត្រូវបានអនុញ្ញាតឱ្យធ្វើឡើងច្រើនលើកនៅក្នុងជុំបង្វិលនីមួយៗ
- ការទូទាត់រជ្ជទេយ្យបុរេប្រទានក្នុងមួយលើក ត្រូវកំណត់ពុំឱ្យលើសពីទំហំទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន
- ទឹកប្រាក់រជ្ជទេយ្យបុរេប្រទានត្រូវបានបំពេញឡើងវិញក្រោយការទូទាត់មួយលើកៗ លើកលែងតែការទូទាត់ក្រោយកាលបរិច្ឆេទនៃការបើកសាច់ប្រាក់ចុងក្រោយដែលកំណត់ដោយសារាចរណែនាំស្តីពីការបិទបញ្ជីចំណូល-ចំណាយថវិកាប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ផ្នែកទី២

## ការតែងតាំងរជ្ជទេយ្យករបុរេប្រទាន

**ប្រការ១០.-**

រជ្ជទេយ្យករបុរេប្រទានអាចមានរជ្ជទេយ្យករបុរេប្រទានរងមួយចំនួនជាជំនួយការតាមការចាំបាច់។

រជ្ជទេយ្យករបុរេប្រទាននិងរជ្ជទេយ្យករបុរេប្រទានរងត្រូវបានតែងតាំងដោយប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួង ស្ថាប័នសាមី តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ។

សេចក្តីព្រាងប្រកាសអន្តរក្រសួងខាងលើត្រូវបានកំណត់ជាឧបសម្ព័ន្ធទី៦នៃប្រកាសនេះ។

**ប្រការ១១.-**

រដ្ឋទេយ្យករបុរេប្រទាននិងរដ្ឋទេយ្យករបុរេប្រទានរងត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ សីលធម៌វិជ្ជាជីវៈខ្ពស់ និងចំណេះដឹងច្បាស់លាស់អំពីកិច្ចបញ្ជិកាគណនេយ្យ ដោយស្របតាមលក្ខខណ្ឌវិនិច្ឆ័យដូចខាងក្រោម÷

- ត្រូវមានចំណេះដឹង ឬ បទពិសោធន៍លើការងារគណនេយ្យយ៉ាងតិច១(មួយ)ឆ្នាំ
- ធ្លាប់ទទួលបានការបណ្តុះបណ្តាលផ្នែកគណនេយ្យនិងហិរញ្ញវត្ថុសាធារណៈពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ជាមនុស្សហ្មត់ចត់ សកម្ម យកចិត្តទុកដាក់នឹងការងារ មានការទទួលខុសត្រូវខ្ពស់ និងមានពេលវេលាគ្រប់គ្រាន់សម្រាប់បំពេញការងារ
- យល់ដឹងអំពីគោលនយោបាយ ច្បាប់ នីតិវិធី និងបទដ្ឋានគតិយុត្តផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ក្នុងករណីមានការផ្លាស់ប្តូរសមាសភាពរដ្ឋទេយ្យករបុរេប្រទាន និង/ឬ រដ្ឋទេយ្យករបុរេប្រទានរង ក្រសួងស្ថាប័ន ត្រូវស្នើសុំតែងតាំងរដ្ឋទេយ្យករបុរេប្រទាននិង/ឬរដ្ឋទេយ្យករបុរេប្រទានរងដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមលក្ខខណ្ឌវិនិច្ឆ័យខាងលើឱ្យបានទាន់ពេលវេលាដើម្បីធានានិរន្តភាពនៃកិច្ចដំណើការចំណាយតាមរដ្ឋទេយ្យបុរេប្រទាន និងអាចគ្រប់គ្រងលើការចំណាយតាមរដ្ឋទេយ្យបុរេប្រទានបានត្រឹមត្រូវប្រកបដោយប្រសិទ្ធភាពខ្ពស់។

ប្រកាសអន្តរក្រសួងស្តីពីការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន ត្រូវផ្ញើជូនគណនេយ្យករសាធារណៈនិងអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ។

## ផ្នែកទី៣

## ការទទួលខុសត្រូវរបស់រដ្ឋទេយ្យករបុរេប្រទាន

**ប្រការ១២.-**

រដ្ឋទេយ្យករបុរេប្រទាននិងរដ្ឋទេយ្យករបុរេប្រទានរងត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនផ្នែករដ្ឋបាល ផ្នែករដ្ឋប្បវេណី ផ្នែកព្រហ្មទណ្ឌ និងជាប្រាក់កាស ចំពោះការទុកដាក់ថែរក្សានូវមូលនិធិដែលខ្លួនបានទទួល ឬបានចំណាយ ការទុកដាក់ថែរក្សាលិខិតយុត្តិការ និងការកាន់កាប់បញ្ជីគណនេយ្យនៃកិច្ចប្រតិបត្តិការ។

## ជំពូកទី៣
## កិច្ចដំណើរការនៃរជ្ជទេយ្យបុរេប្រទាន
### ផ្នែកទី១
### ការដកប្រាក់រជ្ជទេយ្យបុរេប្រទាន

**ប្រការ១៣.-**

បន្ទាប់ពីទទួលការតែងតាំងរួច រជ្ជទេយ្យករបុរេប្រទានត្រូវបំពេញបែបបទស្នើសុំបើកគណនីនៅអគ្គនាយកដ្ឋានរតនាគារជាតិសម្រាប់រដ្ឋបាលថ្នាក់កណ្ដាល ឬនៅរតនាគាររាជធានី ខេត្តសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត។

ក្នុងករណីចាំបាច់ រជ្ជទេយ្យករបុរេប្រទានអាចបើកគណនីនៅធនាគារពាណិជ្ជដៃគូដោយត្រូវមានគោលការណ៍អនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីសម្រួលដល់កិច្ចដំណើការគ្រប់គ្រងចំណាយតាមរជ្ជទេយ្យបុរេប្រទាន។

**ប្រការ១៤.-**

រជ្ជទេយ្យករបុរេប្រទាន នៅពេលបង្កើតរជ្ជទេយ្យបុរេប្រទានរួចរាល់ ត្រូវរក្សាទុកឥណទានថវិកាជាបណ្ដោះអាសន្ន លើសលាកបត្រតាមដានការប្រើប្រាស់ឥណទានថវិកាទៅតាមមាតិកាចំណាយថវិកានៃតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានដែលមានចំនួនទឹកប្រាក់ស្មើនឹងឥណទានថវិការជ្ជទេយ្យបុរេប្រទាន។ ដោយឡែកគណនេយ្យករសាធារណៈត្រូវរក្សាទុកឥណទានថវិកាជាបណ្ដោះអាសន្ន ដែលមានចំនួនទឹកប្រាក់ស្មើនឹងមួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន។

**ប្រការ១៥.-**

ផ្អែកតាមលិខិតអនុញ្ញាតឱ្យបង្កើតរជ្ជទេយ្យបុរេប្រទាន និងបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយជុំបង្វិលដំបូង គណនេយ្យករសាធារណៈត្រូវបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយជុំបង្វិលដំបូងជូនរជ្ជទេយ្យករបុរេប្រទាននាដើមឆ្នាំថវិកានីមួយៗ។ ក្នុងករណីចាំបាច់ តាមសំណើរបស់រជ្ជទេយ្យករបុរេប្រទានឬមានគោលការណ៍កំណត់ដោយឡែកដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណនេយ្យករសាធារណៈអាចធ្វើការផ្ទេរប្រាក់រជ្ជទេយ្យបុរេប្រទានដោយត្រង់ជូនរជ្ជទេយ្យករបុរេប្រទានរង។

### ផ្នែកទី២
### ចំណាយនិងការទូទាត់ប្រាក់រជ្ជទេយ្យបុរេប្រទាន

**ប្រការ១៦.-**

ចំណាយប្រាក់រជ្ជទេយ្យបុរេប្រទានត្រូវមានសក្ខីបត្របញ្ជាក់ត្រឹមត្រូវ។ មុននឹងធ្វើការចំណាយប្រាក់រជ្ជទេយ្យបុរេប្រទាន រជ្ជទេយ្យករបុរេប្រទានត្រូវស្នើសុំគោលការណ៍ចំណាយទៅអាណាប័ក។ ក្រោយពីទទួល

បានគោលការណ៍ចំណាយ រដ្ឋទេយ្យករបុរេប្រទានត្រូវទូទាត់ចំណាយជាប្រាក់រៀល ដោយតម្រូវឱ្យមានសក្ខីបត្របញ្ជាក់អំពីការទទួលបានប្រាក់ ឬ បានទូទាត់ប្រាក់គ្រប់ចំនួន។

**ប្រការ១៧.-**

រាល់ប័ណ្ណចំណាយត្រូវភ្ជាប់មកជាមួយនូវគោលការណ៍ចំណាយ វិក្កយបត្រ ឬ សក្ខីបត្រចំណាយ ដែលរដ្ឋទេយ្យករបុរេប្រទានបានធ្វើការទូទាត់ ដោយមានការបញ្ជាក់ទទួលស្គាល់ពីអាណាប័ក។

អនុញ្ញាតឱ្យរដ្ឋទេយ្យករបុរេប្រទានយកវិក្កយបត្រ ឬ សក្ខីបត្រចំណាយដែលបានចុះកាលបរិច្ឆេទរយៈពេលយ៉ាងយូរ៤៥ថ្ងៃមុនពេលមានប្រាក់ក្នុងបេឡារដ្ឋទេយ្យបុរេប្រទានមកធ្វើជាលិខិតយុត្តិការចំណាយដើម្បីបោះផ្សាយអាណត្តិនិយតកម្ម ប៉ុន្តែប័ណ្ណចំណាយត្រូវចុះកាលបរិច្ឆេទនៅក្រោយពេលបានបំពេញបេឡារដ្ឋទេយ្យបុរេប្រទាន។ ក្នុងករណីវិក្កយបត្រ ឬ សក្ខីបត្រចំណាយបានចុះកាលបរិច្ឆេទលើសពី៤៥ថ្ងៃមុនពេលមានប្រាក់ក្នុងបេឡារដ្ឋទេយ្យបុរេប្រទាន រដ្ឋទេយ្យករបុរេប្រទានត្រូវរាយការណ៍ជូនអាណាប័ក ឬ អាណាប័កផ្ទេរសិទ្ធិដើម្បីស្នើសុំគោលការណ៍ដោយឡែកពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ១៨.-**

ចំនួនទឹកប្រាក់សម្រាប់មួយគោលការណ៍ចំណាយ ឬ មួយប័ណ្ណចំណាយត្រូវបានកំណត់៣ ០០០ ០០០ (បីលាន) រៀលជាអតិបរមា។

មួយគោលការណ៍ចំណាយសំដៅដល់មួយកម្មវត្ថុចំណាយឬមួយគម្រោងចំណាយដែលរដ្ឋទេយ្យករបុរេប្រទានស្នើសុំគោលការណ៍ចំណាយពីអាណាប័កមួយលើកៗដើម្បីចំណាយតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន ។

រដ្ឋទេយ្យករបុរេប្រទាន ឬ រដ្ឋទេយ្យករបុរេប្រទានរងត្រូវជៀសវាងដាច់ខាតនូវការបំបែកគោលការណ៍ចំណាយ ឬ ប័ណ្ណចំណាយទៅតាមទីកន្លែង គោលដៅចំណាយ ពេលវេលា ទឹកប្រាក់ចំណាយ និងសមាសធាតុនៃមុខសញ្ញាចំណាយ ក្នុងគោលបំណងគេចវេះការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ។

**ប្រការ១៩.-**

អាណាប័កត្រូវបោះផ្សាយអាណត្តិនិយតកម្មដោយភ្ជាប់តែរបាយការណ៍ចំណាយ (SOE)តាមរដ្ឋទេយ្យបុរេប្រទានដូចមានគំរូជាឧបសម្ព័ន្ធទី៧នៃប្រកាសនេះ រួចបញ្ជូនទៅអ្នកត្រួតពិនិត្យហិរញ្ញវត្ថុនិងគណនេយ្យករសាធារណៈដើម្បីពិនិត្យទូទាត់។ ចំណែកលិខិតយុត្តិការចំណាយជាច្បាប់ដើមត្រូវរក្សាទុកនៅអង្គភាពដើម (អង្គភាពថវិកា)ជាកម្មវត្ថុនៃការធ្វើអធិការកិច្ច ឬ សវនកម្មតាមក្រោយ។ ក្នុងការពិនិត្យលើឯកសារទូទាត់ ប្រសិនបើអាណាប័កពិនិត្យរបាយការណ៍ចំណាយឃើញថា ចំណាយមួយចំនួនពុំមានលក្ខណៈត្រឹមត្រូវ អាណាប័កអាចហៅរដ្ឋទេយ្យករបុរេប្រទានមកពន្យល់ ឬ បញ្ជូនរបាយការណ៍ចំណាយនោះទៅរដ្ឋទេយ្យករបុរេប្រទានវិញដើម្បីធ្វើការកែតម្រូវ។

ដូច្នេះ ដើម្បីសម្រួលដល់ការអនុវត្តចំណាយរជ្ជទេយ្យបុរេប្រទានបានលឿន មានប្រសិទ្ធភាព និង មានការទទួលខុសត្រូវកាន់តែច្បាស់លាស់ អាណាប័កអាចធ្វើប្រតិភូកម្មពេញលេញនិងទាំងស្រុងឱ្យអង្គភាពថវិកាក្នុងការគ្រប់គ្រងនិងអនុវត្តចំណាយរជ្ជទេយ្យបុរេប្រទាន។

**ប្រការ២០.-**

អ្នកត្រួតពិនិត្យហិរញ្ញវត្ថុនិងគណនេយ្យករសាធារណៈត្រូវពិនិត្យផ្ទៀងផ្ទាត់ អំពីភាពត្រឹមត្រូវនៃការរៀបចំរបាយការណ៍ចំណាយ(SOE)តាមរជ្ជទេយ្យបុរេប្រទានរបស់អាណាប័កដើម្បីផ្តល់ទិដ្ឋាការនិងការទូទាត់ចំណាយតាមរជ្ជទេយ្យបុរេប្រទាន។

ក្នុងករណីពិនិត្យឃើញថាត្រឹមត្រូវហើយ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុត្រូវផ្តល់ទិដ្ឋាការនិងបញ្ជូនអាណត្តិនិយតកម្មនិងរបាយការណ៍ចំណាយតាមរជ្ជទេយ្យបុរេប្រទានទៅគណនេយ្យករសាធារណៈ ដោយភ្ជាប់ជាមួយនូវដីកាអមលិខិតយុត្តិការចំនួន១(មួយ)ច្បាប់ ។ ចំណែកឯគណនេយ្យករសាធារណៈត្រូវពិនិត្យនិងទូទាត់អាណត្តិនិយតកម្ម រួចត្រូវកត់ត្រាជាចំណាយថវិកានិងកត់ត្រាជម្រះចំនួនទឹកប្រាក់នោះនៅក្នុងគណនីរជ្ជទេយ្យករបុរេប្រទាន។

ក្នុងករណីពិនិត្យឃើញថា អាណត្តិនិយតកម្មនិងរបាយការណ៍ចំណាយពុំទាន់មានលក្ខណៈត្រឹមត្រូវ និងមិនអនុលោមតាមបទប្បញ្ញត្តិផ្សេងៗនៃប្រកាសនេះ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុនិងគណនេយ្យករសាធារណៈមានសិទ្ធិស្នើសុំការបញ្ជាក់បំភ្លឺពីអាណាប័ក ឬ ផ្តល់ឯកសារបន្ថែមឬមិនធ្វើការទូទាត់ជូន។ ក្នុងករណីដែលគណនេយ្យករសាធារណៈបដិសេធមិនធ្វើការទូទាត់ជូន ដោយសារពុំបានទទួលការបញ្ជាក់ ឬ ឯកសារបន្ថែមត្រឹមត្រូវនិងគ្រប់គ្រាន់ពីអាណាប័ក គណនេយ្យករសាធារណៈត្រូវបញ្ជូនអាណត្តិនិយតកម្មនោះត្រឡប់ទៅអាណាប័កវិញតាមរយៈអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ដោយមានការបញ្ជាក់អំពីចំណុចខ្វះខាត។ ក្រោយពីកែតម្រូវលើអាណត្តិនិយតកម្ម ឬលិខិតយុត្តិការចំណាយរួច អាណាប័កត្រូវផ្ញើជូនអ្នកត្រួតពិនិត្យហិរញ្ញវត្ថុសាជាថ្មីដើម្បីពិនិត្យនិងបញ្ជូនបន្តមកគណនេយ្យករសាធារណៈ។

បន្ទាប់មក រជ្ជទេយ្យករបុរេប្រទានត្រូវរៀបចំប័ណ្ណស្នើសុំដកប្រាក់រជ្ជទេយ្យបុរេប្រទានពីគណនេយ្យករសាធារណៈដើម្បីបំពេញបេឡារជ្ជទេយ្យបុរេប្រទាន លើកលែងតែការទូទាត់ជម្រះបញ្ជីរជ្ជទេយ្យបុរេប្រទាននៅដំណាច់ឆ្នាំថវិកា។

ការបើកផ្តល់ប្រាក់រជ្ជទេយ្យបុរេប្រទានលើកចុងក្រោយត្រូវកំណត់ដោយសារាចរណែនាំស្តីពីការបិទបញ្ជីចំណូល-ចំណាយថវិកាប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ២១.-**

ក្នុងដំណាក់កាលអន្តរកាល នៅពេលមុខងារស្កែនលិខិតយុត្តិការចំណាយពុំទាន់អាចអនុវត្តក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) បាននៅឡើយ លិខិតយុត្តិការចំណាយដែលជាច្បាប់ដើមត្រូវបានអនុញ្ញាតឱ្យរក្សាទុកនៅសាមីក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល សម្រាប់

ជាកម្មវត្ថុនៃការធ្វើអធិការកិច្ច ឬ សវនកម្ម។ ក្នុងករណីចាំបាច់ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុនិងគណនេយ្យករសាធារណៈមានសិទ្ធិស្នើសុំការបញ្ជាក់ ឬ ឯកសារច្បាប់ដើមពាក់ព័ន្ធបន្ថែម។

នៅពេលមុខងារស្កែនលិខិតយុត្តិការចំណាយអាចអនុវត្តបានក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) លិខិតយុត្តិការចំណាយដែលជាច្បាប់ដើមត្រូវរក្សាទុកនៅសាមីក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែល ដោយត្រូវស្កែនបញ្ចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដើម្បីជាមូលដ្ឋានក្នុងការពិនិត្យដោយអ្នកត្រួតពិនិត្យហិរញ្ញវត្ថុគណនេយ្យករសាធារណៈ និងការធ្វើអធិការកិច្ច ឬ សវនកម្មដោយមន្ត្រីអធិការកិច្ច ឬ សវនករ។

**ប្រការ២២.-**

ចំណាយតាមរជ្ជទេយ្យបុរេប្រទានត្រូវប្រព្រឹត្តទៅតាមវដ្តនៃរជ្ជទេយ្យបុរេប្រទានដែលចែកចេញជា៥ (ប្រាំ) ដំណាក់កាលដូចខាងក្រោម÷

- រជ្ជទេយ្យករបុរេប្រទានដកប្រាក់រជ្ជទេយ្យបុរេប្រទានពីគណនេយ្យករសាធារណៈ
- ចំណាយប្រាក់រជ្ជទេយ្យបុរេប្រទាន
- រជ្ជទេយ្យករបុរេប្រទានរៀបចំលិខិតយុត្តិការចំណាយ ដាក់ជូនអាណាប័កបោះផ្សាយអាណត្តិនិយតកម្មដើម្បីស្នើសុំការទូទាត់
- ទទួលបានទិដ្ឋាការពីអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ
- ទទួលបានការឯកភាពទូទាត់ពីគណនេយ្យករសាធារណៈជាចំណាយថវិកាស្ថាពរ។

កិច្ចដំណើរការចំណាយតាមវដ្តនៃរជ្ជទេយ្យបុរេប្រទានត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់គណនេយ្យករសាធារណៈ។

គំនូសបំព្រួញអំពីវដ្តនៃរជ្ជទេយ្យបុរេប្រទានត្រូវបានកំណត់ដូចខាងក្រោម÷




## ផ្នែកទី៣
## វិធានការអនុវត្តនាពេលដំណាច់ឆ្នាំថវិកា

**ប្រការ២៣.-**

នាពេលដំណាច់ឆ្នាំថវិកា ក្នុងករណីមានប្រាក់រជ្ជទេយ្យបុរេប្រទាននៅសល់ រជ្ជទេយ្យករបុរេប្រទានត្រូវយកប្រាក់ដែលនៅសល់នោះមកបង់ជូនគណនេយ្យករសាធារណៈវិញដើម្បីចុះកិច្ចបញ្ជិកាជម្រះបញ្ជីរជ្ជទេយ្យបុរេប្រទាន។

**ប្រការ២៤.-**

រជ្ជទេយ្យករបុរេប្រទានត្រូវខិតខំប្រមូលលិខិតយុត្តិការចំណាយជូនអាណាប័កដើម្បីធ្វើការបោះផ្សាយអាណត្តិនិយតកម្ម រួចបញ្ជូនមកអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ និងគណនេយ្យករសាធារណៈយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំ ដើម្បីទូទាត់និងជម្រះបញ្ជីរជ្ជទេយ្យបុរេប្រទានឱ្យបានទាន់ក្នុងឆ្នាំថវិកា។

## ជំពូកទី៤

## គណនេយ្យរដ្ឋបេឡាបុរេប្រទាន

**ប្រការ២៥.-**

រដ្ឋទេយ្យករបុរេប្រទានត្រូវចុះកិច្ចបញ្ជិកាគណនេយ្យតាមគោលការណ៍ទ្វេភាគ និងរៀបចំរបាយការណ៍គណនេយ្យរដ្ឋទេយ្យបុរេប្រទាន។ កិច្ចបញ្ជិកាគណនេយ្យនិងរបាយការណ៍គណនេយ្យរដ្ឋទេយ្យបុរេប្រទានត្រូវកត់ត្រានិងរៀបចំជាបន្តបន្ទាប់ចាប់ពីដើមឆ្នាំរហូតដល់ដំណាច់ឆ្នាំថវិកានីមួយៗ។ នៅសប្តាហ៍ទី១នៃខែមករានាដើមឆ្នាំអនុវត្តថវិកា រដ្ឋទេយ្យករបុរេប្រទានត្រូវចាប់ផ្តើមអនុវត្តការគ្រប់គ្រងជាថ្មី ដោយជុំបង្វិលរដ្ឋទេយ្យបុរេប្រទានផ្អែកតាមលិខិតរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលអនុញ្ញាតឱ្យបង្កើត រដ្ឋទេយ្យបុរេ-ប្រទាននិងបើកប្រាក់រដ្ឋទេយ្យបុរេប្រទានមួយជុំបង្វិលដំបូង ស្របតាមតារាងឧបសម្ពន្ធរដ្ឋទេយ្យបុរេប្រទាន។

**ប្រការ២៦.-**

បញ្ជីគណនេយ្យរបស់រដ្ឋទេយ្យករបុរេប្រទានមានដូចខាងក្រោម÷

- បញ្ជីបេឡា÷សម្រាប់កត់ត្រាចំនួនទឹកប្រាក់រដ្ឋទេយ្យបុរេប្រទានដែលបានទទួលពីគណនេយ្យករសាធារណៈ ទឹកប្រាក់ដែលបានចំណាយនិងទឹកប្រាក់ដែលនៅសល់។ បញ្ជីបេឡាមាន២(ពីរ)ដូចខាងក្រោម÷
  - ១-បញ្ជីបេឡានៅធនាគារ÷ កត់ត្រាដោយយោងតាមប្រកាសឥណពន្ធឬប័ណ្ណដកប្រាក់ ប្រកាសឥណទានឬ ប័ណ្ណបង់ប្រាក់ឬរបាយការណ៍របស់ធនាគារ។
  - ២-បញ្ជីបេឡាក្នុងដៃ÷ កត់ត្រាដោយយោងតាមប័ណ្ណចំណូលនិងប័ណ្ណចំណាយ។
- ទិន្នានុប្បវត្តិទូទៅ-សៀវភៅធំ÷ សម្រាប់កត់ត្រាប្រតិបត្តិការរដ្ឋទេយ្យបុរេប្រទានដោយចែកចេញជា ២ (ពីរ)ផ្នែក ដូចខាងក្រោម÷
  - ១-ផ្នែកទិន្នានុប្បវត្តិទូទៅ÷ សម្រាប់កត់ត្រាប្រតិបត្តិការរដ្ឋទេយ្យបុរេប្រទានប្រចាំថ្ងៃទៅតាមលំដាប់ដែលមានជាអាទិ៍លេខរៀង កាលបរិច្ឆេទ ឯកសារយោង(សលាកបត្រចុះលេខនា) លេខគណនី ឬ អនុគណនី បរិយាយទឹកប្រាក់ខាងឥណពន្ធនិងទឹកប្រាក់ខាងឥណទាន។ សរុបចំនួនទឹកប្រាក់នៃចលនាខាងឥណពន្ធត្រូវស្មើនឹងសរុបចំនួនទឹកប្រាក់នៃចលនាខាងឥណទាន។
  - ២-ផ្នែកសៀវភៅធំ÷ សម្រាប់កត់ត្រាប្រតិបត្តិការរដ្ឋទេយ្យបុរេប្រទានប្រចាំថ្ងៃទៅតាមផ្នែកខាងឥណពន្ធនិងផ្នែកខាងឥណទាននៃគណនីរដ្ឋទេយ្យបុរេប្រទាននីមួយៗ។ សៀវភៅធំត្រូវបូកសរុបនៅដំណាច់ខែនីមួយៗដើម្បីជាមូលដ្ឋានក្នុងការរៀបចំតារាងតុល្យភាពគណនីរដ្ឋទេយ្យបុរេប្រទានប្រចាំខែ។

ទិន្នានុប្បវត្តិ-សៀវភៅធំត្រូវមានការចុះហត្ថលេខាដោយរដ្ឋទេយ្យករបុរេប្រទាន អគ្គនាយក/ប្រធាននាយកដ្ឋាន/ ប្រធានការិយាល័យគណនេយ្យ និងអាណាប័ក។

របាយការណ៍គណនេយ្យរជ្ជទេយ្យបុរេប្រទានរួមមានតារាងតុល្យភាពគណនីរជ្ជទេយ្យបុរេប្រទានប្រចាំខែ និងប្រចាំឆ្នាំដែលមានហត្ថលេខារបស់រជ្ជទេយ្យករបុរេប្រទាន អគ្គនាយក/ប្រធាននាយកដ្ឋាន/ប្រធានការិយាល័យគណនេយ្យ និងអាណាប័ក ហើយត្រូវផ្ញើទៅគណនេយ្យករសាធារណៈដោយភ្ជាប់មកជាមួយនូវទិន្នានុប្បវត្តិ- សៀវភៅធំ ចំនួន១(មួយ)ច្បាប់ឱ្យបានយ៉ាងយូរត្រឹមថ្ងៃទី១៥នៃខែបន្ទាប់។

សារាចរណែនាំលម្អិតស្តីពីកិច្ចបញ្ជិកាគណនេយ្យរជ្ជទេយ្យបុរេប្រទានត្រូវចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី៥

## ការត្រួតពិនិត្យរជ្ជទេយ្យបុរេប្រទាន

## ផ្នែកទី១

## គោលការណ៍ទូទៅ

**ប្រការ២៧.-**

រជ្ជទេយ្យបុរេប្រទានទាំងអស់ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យនៃអាណាប័ករបស់ខ្លួន។ ទន្ទឹមនេះ រជ្ជទេយ្យករបុរេប្រទានត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យផ្ទៀងផ្ទាត់ពីអគ្គាធិការដ្ឋាននិងអាជ្ញាធរមានសមត្ថកិច្ចត្រួតពិនិត្យនៅនឹងកន្លែង។

## ផ្នែកទី២

## ការត្រួតពិនិត្យលើលិខិតយុត្តិការ

**ប្រការ២៨.-**

អាណាប័កមានភារកិច្ចត្រួតពិនិត្យដូចតទៅ÷

- អាណាប័កតម្រូវឱ្យរជ្ជទេយ្យករបុរេប្រទានផ្តល់នូវតារាងតុល្យភាពគណនីនៃរជ្ជទេយ្យបុរេប្រទានប្រចាំខែនិងប្រចាំឆ្នាំ ព្រមទាំងរបាយការណ៍និងកំណត់ហេតុត្រួតពិនិត្យផ្ទាល់នៅនឹងកន្លែងលើការងាររជ្ជទេយ្យ បុរេប្រទាន ដែលបានធ្វើឡើងដោយគណនេយ្យករមុខការ
- អាណាប័កត្រូវពិនិត្យលិខិតយុត្តិការចំណាយដែលផ្តល់ដោយរជ្ជទេយ្យករបុរេប្រទាននិងត្រូវធានាថាឯកសារទាំងឡាយមានការប្រគល់និងទទួលត្រឹមត្រូវពិតប្រាកដរវាងរជ្ជទេយ្យករបុរេប្រទាន និងអ្នកទទួលប្រាក់ ព្រមទាំងពិនិត្យថា រជ្ជទេយ្យករបុរេប្រទានបានទូទាត់តែមុខសញ្ញាចំណាយដែលអនុញ្ញាតឱ្យចំណាយតាមរជ្ជទេយ្យបុរេប្រទានប៉ុណ្ណោះ។

**ប្រការ២៩.-**

អ្នកត្រួតពិនិត្យហិរញ្ញវត្ថុមានភារកិច្ចត្រួតពិនិត្យអាណត្តិនិយតកម្ម របាយការណ៍ចំណាយថវិការជ្ជទេយ្យបុរេប្រទាន និងតារាងតុល្យភាពគណនីនៃរជ្ជទេយ្យបុរេប្រទានដែលផ្តល់ដោយអាណាប័ក និងផ្តល់ទិដ្ឋាការ។

អ្នកត្រួតពិនិត្យហិរញ្ញវត្ថុត្រូវពិនិត្យមើលថា អាណាប័កទូទាត់តែមុខសញ្ញាចំណាយណាដែលអនុញ្ញាតឱ្យចំណាយតាមរជ្ជទេយ្យបុរេប្រទានប៉ុណ្ណោះ។

**ប្រការ៣០.-**

គណនេយ្យករសាធារណៈមានភារកិច្ចត្រួតពិនិត្យអាណត្តិនិយតកម្ម របាយការណ៍ចំណាយថវិការជ្ជទេយ្យបុរេប្រទាន តារាងតុល្យភាពគណនីនៃរជ្ជទេយ្យបុរេប្រទាន និងផ្តល់ការទូទាត់។ គណនេយ្យករសាធារណៈត្រូវពិនិត្យមើលថា អាណាប័កទូទាត់តែមុខសញ្ញាចំណាយណាដែលអនុញ្ញាតឱ្យចំណាយតាមរជ្ជទេយ្យបុរេប្រទានប៉ុណ្ណោះ។

## ផ្នែកទី៣
## ការត្រួតពិនិត្យដល់ទីកន្លែង

**ប្រការ៣១.-**

អាណាប័ក គណនេយ្យករសាធារណៈ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ អគ្គាធិការ និងមន្ត្រីនៃស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត អាចធ្វើការត្រួតពិនិត្យ ឬ ផ្ទៀងផ្ទាត់នៅនឹងកន្លែងដោយផ្ទាល់លើការងារគ្រប់គ្រងរបស់រជ្ជទេយ្យករបុរេប្រទាន។ ការត្រួតពិនិត្យត្រូវប្រព្រឹត្តទៅដោយពុំប្រាប់ឱ្យដឹងជាមុន។ អាណាប័ក អាចចាត់តាំងតំណាង ឬ អង្គភាពនៅក្រោមឱវាទដើម្បីធ្វើការត្រួតពិនិត្យផ្ទាល់នៅនឹងកន្លែង។

ការត្រួតពិនិត្យខាងលើត្រូវធ្វើលើចំណុចជាអាទិ៍ដូចខាងក្រោម÷

- អត្ថិភាពចំណាយនិងតម្លៃ
- ការបញ្ជប់និងផ្តល់ទិដ្ឋាការលើបញ្ជីទាំងឡាយ
- ការរៀបចំតារាងតុល្យភាពគណនីរជ្ជទេយ្យបុរេប្រទាន
- កិច្ចប្រតិបត្តិការគណនេយ្យនិងលិខិតយុត្តិការផ្សេងៗដែលមានការពាក់ព័ន្ធទៅនឹងការរៀបចំ និងកិច្ចដំណើរការរបស់រជ្ជទេយ្យបុរេប្រទាន។

ក្រៅពីស្ថាប័នមានសមត្ថកិច្ចដែលកំណត់ដោយច្បាប់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមាននីតិសម្បទាក្នុងការចាត់ឱ្យមានការត្រួតពិនិត្យលើចំណាយតាមរជ្ជទេយ្យបុរេប្រទាន តាមសំណើរបស់អ្នកត្រួតពិនិត្យហិរញ្ញវត្ថុនិង/ឬគណនេយ្យករសាធារណៈ។ ការត្រួតពិនិត្យនេះត្រូវមានសមាសភាពមកពីអ្នកត្រួតពិនិត្យហិរញ្ញវត្ថុនិងគណនេយ្យករសាធារណៈ ដែលមានលិខិតបញ្ជាបេសកកម្មត្រឹមត្រូវ។

**ប្រការ៣២.-**

ការត្រួតពិនិត្យដោយអាណាប័កត្រូវធ្វើឱ្យបានញឹកញាប់និងជាប្រចាំ។ ជាគោលការណ៍ ការត្រួតពិនិត្យលើអត្ថិភាពចំណាយនិងតម្លៃដែលបានអនុវត្ត គឺត្រូវធ្វើក្នុង១(មួយ)ត្រីមាសម្តង។

ការត្រួតពិនិត្យរបស់គណនេយ្យករសាធារណៈនិងអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវធ្វើឡើងដោយឈរលើគោលការណ៍គ្រប់គ្រងហានិភ័យតាមការចាត់តាំងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រាល់ពេលត្រួតពិនិត្យមួយលើកៗ ត្រូវមានរបាយការណ៍ឬកំណត់ហេតុត្រឹមត្រូវច្បាស់លាស់ ដែលក្នុងនោះត្រូវកត់សម្គាល់នូវកិច្ចការដែលបានពិនិត្យឃើញ។ ឯកសារទាំងនោះត្រូវផ្តល់ឱ្យរដ្ឋទេយ្យករបុរេប្រទានធ្វើការកត់សម្គាល់និងផ្តល់នូវចម្លើយ ហើយត្រូវផ្ញើត្រលប់ទៅភ្នាក់ងារត្រួតពិនិត្យនិងអាណាប័កវិញ។

## ជំពូកទី៦

## អន្តរប្បញ្ញត្តិ

**ប្រការ៣៣.-**

ឥណទានថវិការដ្ឋទេយ្យបុរេប្រទានដែលទទួលបានការអនុម័តសម្រាប់អនុវត្តឆ្នាំ២០២០ ត្រូវបានអនុញ្ញាតឱ្យអនុវត្តតាមបទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុដែលមានជាធរមាន។

**ប្រការ៣៤.-**

ការរៀបចំផែនការឥណទានថវិការដ្ឋទេយ្យបុរេប្រទានសម្រាប់ឆ្នាំ២០២១ ត្រូវអនុវត្តតាមប្រតិទិន នៃការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលត្រូវចាប់ផ្តើមពីខែមីនា ឆ្នាំ២០២០។

ប្រកាសស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិនេះ មានប្រសិទ្ធភាពអនុវត្តពេញលេញចាប់ពីឆ្នាំ២០២១ តទៅ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**ប្រការ៣៥.-**

ត្រូវបាននិរាករណ៍លិខិតបទដ្ឋានគតិយុត្តដូចខាងក្រោម÷

- ប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- សារាចរណែនាំលេខ ០០៤ សហវ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការបង្កើតតារាងឧបសម្ពន្ធរដ្ឋទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធី
- សារាចរណែនាំលេខ ០០២ សហវ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីកិច្ចបញ្ជិកាគណនេយ្យរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣៦.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៨ កើត ខែទុតិយាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពប្រហាក់ប្រហែលនៃរដ្ឋបាលថ្នាក់ជាតិ
- ដូចប្រការ៣៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១**

(ឧបសម្ព័ន្ធភ្ជាប់តាមប្រកាសលេខ ៦៦៣ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០២០
ស្ដីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ)

## តារាងកម្រិតកំណត់ទំហំទឹកប្រាក់តាមមុខសញ្ញាចំណាយសម្រាប់ការរៀបចំតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន

| ជំពូក | គណនី | អនុគណនី | បរិយាយ | កម្រិតកំណត់ទំហំទឹកប្រាក់តាមមុខសញ្ញាចំណាយ |
|---|---|---|---|---|
| 60 | | | **ការទិញ** | |
| | 6001 | | **សម្ភារផ្គត់ផ្គង់ថែទាំ** | |
| | | 60011 | សម្ភារផ្គត់ផ្គង់សម្អាត និងអនាម័យ | អាចបង្កើតរជ្ជទេយ្យ ១០០% |
| | | 60012 | សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ | មិនលើស៣០% |
| | | 60013 | សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំផ្លូវថ្នល់ ស្ពាន និងលូ | មិនលើស៣០% |
| | | 60014 | សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារឧបករណ៍ | មិនលើស៣០% |
| | | 60018 | សម្ភារផ្គត់ផ្គង់ថែទាំផ្សេងៗ | មិនលើស៣០% |
| | 6002 | | **សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល** | |
| | | 60021 | សម្ភារការិយាល័យ | មិនលើស៣០% |
| | | 60022 | សៀវភៅមើល និងឯកសារ | មិនលើស៣០% |
| | | 60023 | ការបោះពុម្ព | មិនលើស៣០% |
| | | 60028 | សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ | មិនលើស៣០% |
| | 6003 | | **ស្បៀងអាហារ និងផលិតផលកសិកម្ម** | |
| | | 60037 | ស្បៀងសម្រាប់រដ្ឋបាល | មិនលើស៣០% |
| | 6005 | | **សម្ភារតូចតាច សង្ហារឹម និងសម្ភារបរិក្ខារ** | |
| | | 60051 | សម្ភារនិងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា | មិនលើស៣០% |
| | | 60052 | សង្ហារិម | មិនលើស៣០% |
| | | 60053 | សម្ភារប្រើប្រាស់ | មិនលើស៣០% |
| | | 60055 | សម្ភារនិងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា | មិនលើស៣០% |
| | | 60058 | សម្ភារតូចតាច សង្ហារឹម និងសម្ភារបរិក្ខារផ្សេងៗ | មិនលើស៣០% |
| | 6102 | | **ការជួលមធ្យោបាយដឹកជញ្ជូន** | |
| | | 61021 | ការជួលមធ្យោបាយដឹកជញ្ជូន | មិនលើស៣០% លើកលែងតែចំណាយជួលសេវាដឹកជញ្ជូនពីក្រុមហ៊ុន Royal Cambodian Limousine Service Co., Ltd ដែលមិនអនុញ្ញាតឱ្យបង្កើតរជ្ជទេយ្យ. |
| | 6105 | | **ការថែទាំនិងជួសជុល** | |
| | | 61054 | ការថែទាំបណ្ដាញផ្សេងៗ | មិនលើស៣០% |
| | | 61056 | ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន | មិនលើស៣០% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារ និងឧបករណ៍បច្ចេកទេស | មិនលើស៣០% |
| | | 61058 | ការថែទាំនិងជួសជុលផ្សេងៗ | មិនលើស៣០% |

| ជំពូក | គណនី | អនុគណនី | បរិយាយ | កម្រិតកំណត់ទំហំទឹកប្រាក់តាមមុខសញ្ញាចំណាយ |
|---|---|---|---|---|
| | **6108** | | **សោហ៊ុយដឹកជញ្ជូន** | |
| | | 61081 | សម្ភារ និងទំនិញ | មិនលើស៣០% |
| | | 61088 | សោហ៊ុយដឹកជញ្ជូនផ្សេងៗ | មិនលើស៣០% |
| | **6110** | | **ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ** | |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | មិនលើស៣០% |
| | | 61102 | សោហ៊ុយទទួលភ្ញៀវបរទេស | មិនលើស៣០% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | មិនលើស៣០% |
| | | 61105 | ចំណាយសម្រាប់វត្ថុអនុស្សាវរីយ៍ នៅក្នុងនិងក្រៅប្រទេស | មិនលើស៣០% |
| | | 61107 | ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ | មិនលើស៣០% |
| | | 61108 | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយផ្សេងៗ | មិនលើស៣០% |
| | **6111** | | **សារព័ត៌មាន និងឯកសារ** | |
| | | 61111 | ចំណាយលើការជាវសារព័ត៌មាន | អាចបង្កើតរជ្ជទេយ្យ ១០០% |
| | | 61112 | ចំណាយលើការជាវទស្សនាវដ្ដី | អាចបង្កើតរជ្ជទេយ្យ ១០០% |
| | | 61118 | ចំណាយលើការជាវសារព័ត៌មាន និងឯកសារផ្សេងៗ | អាចបង្កើតរជ្ជទេយ្យ ១០០% |
| | **6114** | | **សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍** | |
| | | 61141 | សោហ៊ុយប្រៃសណីយ៍ | មិនលើស៣០% |
| 65 | | | **ឧបត្ថម្ភធន** | |
| | **6502** | | **ឧបត្ថម្ភធនដល់អង្គការសាធារណៈ** | |
| | | 65021 | ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈសេដ្ឋកិច្ច | មិនលើស៣០% |
| | | 65022 | ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈសង្គម | មិនលើស៣០% |
| | | 65023 | ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈអប់រំ និងកីឡា | មិនលើស៣០% |
| | | 65024 | ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈសន្តិសុខនិងសណ្តាប់ធ្នាប់សង្គម | មិនលើស៣០% |
| | | 65025 | ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈវប្បធម៌ | មិនលើស៣០% |
| | | 65026 | ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈរដ្ឋបាល | មិនលើស៣០% |
| | | 65027 | ឧបត្ថម្ភធនដល់អង្គភាពដែលមានលក្ខណៈច្បាប់ | មិនលើស៣០% |

ឧបសម្ពន្ធទី២.១.១ (សម្រាប់ក្រសួង ស្ថាប័ន និងអង្គភាពថវិកានៅថ្នាក់កណ្តាល)

(ឧបសម្ពន្ធភ្ជាប់តាមប្រកាសលេខ [illegible] សហវ.ប្រក ចុះថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ [illegible] ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង ស្ថាប័ន.....

## តារាងឧបសម្ពន្ធរជ្ជទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់សេដ្ឋកិច្ចសម្រាប់ឆ្នាំ.....

## របស់ក្រសួង ស្ថាប័ន អង្គភាពថវិកា.....

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ... | ឥណទាន ដែលជ្រើសរើស | ឥណទាន រជ្ជទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ត្រង់ | ឥណទាន០១ជុំបង្វិល រជ្ជទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤= ២- ៣ | ៥= ៣/ ៤ជុំ | ៦= ៣/ ២ |
| | | | **សរុបរួម** | | | | | | |
| 60 | | | ការទិញ | | | | | | |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | | | | | | |
| | | 60011 | | | | | | | |
| | ..... | ..... | | | | | | | |
| 61 | | | សេវាកម្ម | | | | | | |
| | ..... | ..... | | | | | | | |
| 65 | | | ឧបត្ថម្ភធន | | | | | | |
| | ..... | ..... | | | | | | | |

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ.....ខែ....ឆ្នាំ.....ព.ស.....
ថ្ងៃទី.....ខែ.......ឆ្នាំ....
អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ.....ខែ....ឆ្នាំ.....ព.ស.....
ថ្ងៃទី.....ខែ.......ឆ្នាំ....
អគ្គនាយក
អគ្គនាយកដ្ឋានថវិកា

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ.....ខែ....ឆ្នាំ.....ព.ស.....
ថ្ងៃទី.....ខែ.......ឆ្នាំ....
អគ្គនាយក/ ប្រធាននាយកដ្ឋាន/ ប្រធាន
ការិយាល័យ...

ថ្ងៃ.....ខែ....ឆ្នាំ.....ព.ស.....
ថ្ងៃទី.....ខែ.......ឆ្នាំ....
រជ្ជទេយ្យករបុរេប្រទាន

បានឃើញនិងឯកភាព
ថ្ងៃ.....ខែ....ឆ្នាំ.....ព.ស.....
ថ្ងៃទី.....ខែ.......ឆ្នាំ....
អាណាប័ក ឬ អាណាប័កផ្ទេរសិទ្ធិ

ឧបសម្ពន្ធទី២.១.២ (សម្រាប់មន្ទីរជំនាញរាជធានី ខេត្ត)

(ឧបសម្ពន្ធភ្ជាប់តាមប្រកាសលេខ ១៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែ[illegible] ឆ្នាំ[illegible] ស្ដីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង ស្ថាប័ន.....

មន្ទីរ....

## តារាងឧបសម្ពន្ធរជ្ជទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់សេដ្ឋកិច្ចសម្រាប់ឆ្នាំ.....

### របស់មន្ទីរ.....

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ... | ឥណទាន ដែលជ្រើសរើស | ឥណទាន រជ្ជទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ត្រង់ | ឥណទាន០១ជុំបង្វិល រជ្ជទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤= ២- ៣ | ៥= ៣/ ៤ជុំ | ៦= ៣/ ២ |
| | | | **សរុបរួម** | | | | | | |
| 60 | | | ការទិញ | | | | | | |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | | | | | | |
| | | 60011 | | | | | | | |
| | ..... | ..... | | | | | | | |
| 61 | | | សេវាកម្ម | | | | | | |
| | ..... | ..... | | | | | | | |
| 65 | | | ឧបត្ថម្ភធន | | | | | | |
| | ..... | ..... | | | | | | | |

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ..... ខែ.... ឆ្នាំ..... ព.ស.....
ថ្ងៃទី..... ខែ....... ឆ្នាំ....
ប្រធានរតនាគាររាជធានី ខេត្ត...

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ..... ខែ.... ឆ្នាំ..... ព.ស.....
ថ្ងៃទី..... ខែ....... ឆ្នាំ....
ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត...

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ..... ខែ.... ឆ្នាំ..... ព.ស.....
ថ្ងៃទី..... ខែ....... ឆ្នាំ....
ប្រធានមន្ទីរ...... រាជធានី ខេត្ត......

ថ្ងៃ..... ខែ.... ឆ្នាំ..... ព.ស.....
ថ្ងៃទី..... ខែ....... ឆ្នាំ...
រជ្ជទេយ្យករបុរេប្រទាន

ឧបសម្ពន្ធទី២.១.៣ (សម្រាប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត)

(ឧបសម្ពន្ធភ្ជាប់តាមប្រកាសលេខ...១៦៧...សហវ.ប្រក ចុះថ្ងៃទី...២៧... ខែ...កក្កដា... ឆ្នាំ...២០២១... ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ....

## តារាងឧបសម្ពន្ធរជ្ជទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់សេដ្ឋកិច្ចសម្រាប់ឆ្នាំ.....

## របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ.....

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ... | ឥណទាន ដែលជ្រើសរើស | ឥណទាន រជ្ជទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ត្រង់ | ឥណទាន០១ជុំបង្វិល រជ្ជទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤= ២- ៣ | ៥= ៣/ ៤ជុំ | ៦= ៣/ ២ |
| | | | សរុបរួម | | | | | | |
| 60 | | | ការទិញ | | | | | | |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | | | | | | |
| | | 60011 | | | | | | | |
| | ..... | ..... | | | | | | | |
| 61 | | | សេវាកម្ម | | | | | | |
| | ..... | ..... | | | | | | | |
| 65 | | | ឧបត្ថម្ភធន | | | | | | |
| | ..... | ..... | | | | | | | |

បានឃើញនិងឯកភាព
ថ្ងៃ.....ខែ....ឆ្នាំ.....ព.ស.....
ថ្ងៃទី.....ខែ.......ឆ្នាំ....
រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ.....ខែ....ឆ្នាំ.....ព.ស.....
ថ្ងៃទី.....ខែ.......ឆ្នាំ....
អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ

ថ្ងៃ.....ខែ....ឆ្នាំ.....ព.ស.....
ថ្ងៃទី.....ខែ.......ឆ្នាំ....
ប្រធានរតនាគាររាជធានី ខេត្ត....

ថ្ងៃ.....ខែ....ឆ្នាំ.....ព.ស.....
ថ្ងៃទី.....ខែ.......ឆ្នាំ....
ប្រធានមន្ទីរសហវ រាជធានី ខេត្ត...

ថ្ងៃ.....ខែ....ឆ្នាំ.....ព.ស.....
ថ្ងៃទី.....ខែ.......ឆ្នាំ....
រជ្ជទេយ្យករបុរេប្រទាន

**ឧបសម្ពន្ធទី២.២.១ (សម្រាប់ក្រសួង ស្ថាប័ន និងអង្គភាពថវិកានៅថ្នាក់កណ្តាល)**

(ឧបសម្ពន្ធភ្ជាប់តាមប្រកាសលេខ ០៦៣ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០២០ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួង ស្ថាប័ន.....

**តារាងឧបសម្ពន្ធរជ្ជទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់កម្មវិធីសម្រាប់ឆ្នាំ.....**

**របស់ក្រសួង ស្ថាប័ន អង្គភាពថវិកា.....**

| ជំពូក | គណនី | អនុគណនី | បរិយាយ | កម្មវិធីទី.... | | | | | | អនុកម្មវិធីទី.... | | | | | | ចង្កោមសកម្មភាពទី... | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានរជ្ជទេយ្យបុរេប្រទាន | ឥណទានទូទាត់ត្រង់ | ឥណទាន០១ដុំបង្វិលរជ្ជទេយ្យបុរេប្រទាន | ភាគរយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានរជ្ជទេយ្យបុរេប្រទាន | ឥណទានទូទាត់ត្រង់ | ឥណទាន០១ដុំបង្វិលរជ្ជទេយ្យបុរេប្រទាន | ភាគរយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានរជ្ជទេយ្យបុរេប្រទាន | ឥណទានទូទាត់ត្រង់ | ឥណទាន០១ដុំបង្វិលរជ្ជទេយ្យបុរេប្រទាន | ភាគរយ |
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ដុំ | ៦=៣/២ | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ដុំ | ៦=៣/២ | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ដុំ | ៦=៣/២ |
| | | | **សរុបរួម** | | | | | | | | | | | | | | | | | | |
| 60 | | | ការទិញ | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| 61 | | | សេវាកម្ម | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| 65 | | | ឧបត្ថម្ភធន | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |

បានឃើញនិងឯកភាព
ថ្ងៃ.....ខែ....ឆ្នាំ.....ព.ស.....
ថ្ងៃទី.....ខែ.......ឆ្នាំ....
អាណាប័ក ឬ អាណាប័កផ្ទេរសិទ្ធិ

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃ.....ខែ....ឆ្នាំ.....ព.ស.....
ថ្ងៃទី.....ខែ.......ឆ្នាំ....
អគ្គនាយក/ប្រធាននាយកដ្ឋាន/ប្រធានការិយាល័យ...

ថ្ងៃ.....ខែ....ឆ្នាំ.....ព.ស.....
ថ្ងៃទី.....ខែ.......ឆ្នាំ....
រជ្ជទេយ្យករបុរេប្រទាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ឧបសម្ព័ន្ធទី២.២.២ (សម្រាប់មន្ទីរជំនាញរាជធានី ខេត្ត)**

(ឧបសម្ព័ន្ធភ្ជាប់តាមប្រកាសលេខ [illegible] សហវ.ប្រក ចុះថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ [illegible] ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ)

ក្រសួង ស្ថាប័ន.....
មន្ទីរ...

**តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានតាមចំណាត់ថ្នាក់កម្មវិធីសម្រាប់ឆ្នាំ.....**

**របស់មន្ទីរ.....**

| ជំពូក | គណនី | អនុគណនី | បរិយាយ | កម្មវិធី.... | | | | | | អនុកម្មវិធី.... | | | | | | ចង្កោមសកម្មភាពទី... | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានរជ្ជទេយ្យបុរេប្រទាន | ឥណទានទូទាត់ត្រង់ | ឥណទាន០១ដុំបង្វិលរជ្ជទេយ្យបុរេប្រទាន | ភាគរយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានរជ្ជទេយ្យបុរេប្រទាន | ឥណទានទូទាត់ត្រង់ | ឥណទាន០១ដុំបង្វិលរជ្ជទេយ្យបុរេប្រទាន | ភាគរយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ... | ឥណទានដែលជ្រើសរើស | ឥណទានរជ្ជទេយ្យបុរេប្រទាន | ឥណទានទូទាត់ត្រង់ | ឥណទាន០១ដុំបង្វិលរជ្ជទេយ្យបុរេប្រទាន | ភាគរយ |
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ដុំ | ៦=៣/២ | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ដុំ | ៦=៣/២ | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ដុំ | ៦=៣/២ |
| | | | **សរុបរួម** | | | | | | | | | | | | | | | | | | |
| 60 | | | ការទិញ | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| 61 | | | សេវាកម្ម | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |
| 65 | | | ឧបត្ថម្ភធន | | | | | | | | | | | | | | | | | | |
| | ..... | ..... | | | | | | | | | | | | | | | | | | | |

បានឃើញនិងឯកភាព
ថ្ងៃ.....ខែ....ឆ្នាំ.....ព.ស.....
ថ្ងៃទី.....ខែ.......ឆ្នាំ....
អាណាប័កផ្ទេរសិទ្ធិ/ប្រធានមន្ទីរ...

ថ្ងៃ.....ខែ....ឆ្នាំ.....ព.ស.....
ថ្ងៃទី.....ខែ.......ឆ្នាំ....
រជ្ជទេយ្យករបុរេប្រទាន

**ឧបសម្ព័ន្ធទី៣.១**

(ឧបសម្ព័ន្ធភ្ជាប់តាមប្រកាសលេខ...៦៦៣... សហវ.ប្រក ចុះថ្ងៃទី...២៨... ខែ...កក្កដា... ឆ្នាំ...២០២០
ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ)

**សូមគោរពជូន**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ៖** សំណើសុំបង្កើតរជ្ជទេយ្យបុរេប្រទាន និងបើកប្រាក់រជ្ជទេយ្យបុរេប្រទានមួយជុំបង្វិលដំបូងសម្រាប់ឆ្នាំ.... របស់ក្រសួង ស្ថាប័ន អង្គភាពថវិកា......។

